## **គំរូសារផ្តល់ព័ត៌មាន និងព្រមាន**

ខាងក្រោមគឺជាគំរូសារដែលទីភ្នាក់ងារផ្តល់ព័ត៌មានអាចប្រើប្រាស់ជាគម្រូយដើម្បីរៀបចំសរសេរសារមួយចំនួនពាក់ព័ន្ធនឹងគ្រោះអាសន្នក្នុងមូលដ្ឋាន។ គំរូទាំងនេះពុំមានលក្ខណៈគ្រប់ជ្រុងជ្រោយឡើយ។ សារចុងក្រោយគួរធ្វើការកែតម្រូវឱ្យស្របតាមតម្រូវការជាក់លាក់នៃព្រឹត្តការណ៍ពិសេសពាក់ព័ន្ធនឹងភាពចាំបាច់នៃព្រឹត្តការណ៍ទាំងនោះ។

### **គំរូសារសម្រាប់ការជម្លៀស**

*សារវែង*

• នេះគឺជា [Agency] ដែលមានបទបញ្ជាជម្លៀសសម្រាប់ [location]។ សូមអនុវត្តវិធានការការពារខាងក្រោម និងត្រូវចាកចេញជាបន្ទាន់ 1. ប្រមូលសមាជិកគ្រួសារមកជុំគ្នា។ 2. ប្រមូលសត្វចិញ្ចឹមទាំងអស់។ 3. ប្រមូលតែរបស់របរសំខាន់ៗ។ 4. យកថ្នាំពេទ្យសំខាន់ៗដាក់ជាប់ខ្លួន 5. បិទគ្រប់ឧបករណ៍ និងភ្លើងទាំងអស់នៅក្នុងផ្ទះ 6. ចាក់សោរផ្ទះ។ ផ្លូវជម្លៀសគឺៈ [Evacuation Route]។ មជ្ឈមណ្ឌលជម្លៀសគឺបើកនៅ [Name and Location of Evacuation Center]។ សម្រាប់ព័ត៌មានបន្ថែម សូមតាមដានស្តាប់វិទ្យុ និងទូរទស្សន៍ក្នុងមូលដ្ឋាន បើកមើល **[url]** ឬទូរសព្ទទៅកាន់ **[###-###-####]**។

• [Agency] កំពុងចេញបទបញ្ជាជម្លៀសសម្រាប់ [location]។ សេវាព័ត៌មានអាកាសធាតុជាតិបានចេញសារព្រមានអំពីទឹកជំនន់សម្រាប់ [location]។ ប្រជាជនទាំងអស់នៅក្នុងតំបន់រងការប៉ះពាល់គួរជម្លៀសចេញជាបន្ទាន់។ មជ្ឈមណ្ឌលជម្លៀស/ជម្រកសុវត្ថិភាពមាននៅ [location]។ សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់ [insert resource]។ សូមបើកស្តាប់ [radio station] ដើម្បីទទួលបានព័ត៌មានថ្មីៗ។

*សារខ្លី*

• ការគំរាមកំហែងភ្លើងឆេះព្រៃ-បទបញ្ជាជម្លៀសសម្រាប់ [location]-សូមចាកចេញឥលូវនេះ -ព័ត៌មានលម្អិតនៅលើគេហទំព័រ [Agency]

### **គំរូសារអំពីជម្រកសុវត្ថិភាព**

*សារវែង*

• [Agency] សូមរាយការណ៍អំពីជម្រកសុវត្ថិភាពសម្រាប់ពលរដ្ឋនៅ [location] ដោយសារមានការសាយភាយសារធាតុគ្រោះថ្នាក់។ សូមអនុវត្តវិធានការការពារខ្លួនជាបន្ទាន់ៈ 1. ចូលក្នុងផ្ទះ ឬអគាររបស់អ្នកជាបន្ទាន់។ 2. យកសត្វចិញ្ចឹមចូលក្នុងផ្ទះប្រសិនបើអ្នកអាចធ្វើបានលឿន។ 3. បិទបង្អួច និងទ្វារទាំងអស់ 4. បិទម៉ាស៊ីនត្រជាក់ និងប្រព័ន្ធម៉ាស៊ីនកម្តៅ។
5. បិទគម្របទ្វារកន្លែងដុតភ្លើង។ 6. ប្រមូលវិទ្យុ ពិល អាហារ ទឹក និងថ្នាំពេទ្យ។ 7. សូមទាក់ទងទៅលេខ 911 ប្រសិនបើអ្នកពិតជាមានស្ថានភាពអាសន្នមែន។ អ្នកនឹងទទួលបានដំណឹងអំពីពេលវេលាដែលស្ថានភាពគ្រោះថ្នាក់នេះកន្លងផុត និងអាចចេញក្រៅដោយសុវត្ថិភាព ឬអាចបំពេញកិច្ចការដូចធម្មតាឡើងវិញ។ សម្រាប់ព័ត៌មានបន្ថែម សូមតាមដានស្តាប់វិទ្យុ និងទូរទស្សន៍ក្នុងមូលដ្ឋាន បើកមើល **[url]** ឬទូរសព្ទទៅកាន់ **[###-###-####]**។

• នាយកដ្ឋានអគ្គិភ័យសូមស្នើឱ្យពលរដ្ឋទាំងអស់ស្ថិតនៅក្នុងកាំរង្វង់ ½ ម៉ាយល៍នៃ [location] ដើម្បីចូលក្នុង និងស្ថិតនៅខាងក្នុងដោយសារការសាយភាយសារធាតុគ្រោះថ្នាក់។ សូមកុំចេញក្រៅ សូមបិទបង្អួច បិទម៉ាស៊ីនត្រជាក់ និងប្រមូលសត្វចិញ្ចឹមរបស់អ្នកដាក់ក្នុងផ្ទះ។ សម្រាប់ព័ត៌មានបន្ថែម សូមតាមដាន **[link]**

*សារខ្លី*

• មានសាយភាយសារធាតុគ្រោះថ្នាក់។ ទាំងអស់គ្នានៅក្នុងចម្ងាយ ½ ម៉ាយល៍ពី [location]។សូមចូលក្នុង។ សូមកុំចេញក្រៅ។ សូមបន្តតាមដានព័ត៌មាន។

### **គំរូសារការយល់ដឹងអំពីអាកាសធាតុ**

*សារវែង*

• [Agency] សូមរាយការណ៍អំពីបទបញ្ជាជម្លៀសសម្រាប់ [location] ដោយសារអាចនឹងមានគ្រោះទឹកជំនន់កើតឡើង។ សូមអនុវត្តវិធានការការពារខាងក្រោម និងត្រូវចាកចេញជាបន្ទាន់ 1. ប្រមូលសមាជិកគ្រួសារទាំងអស់ ឬអ្នកដទៃទៀតឱ្យមកជួបជុំគ្នា 2. ប្រមូលសត្វចិញ្ចឹមទាំងអស់។ 3. ប្រមូលតែរបស់របរសំខាន់ៗ។ 4. យកថ្នាំពេទ្យសំខាន់ៗដាក់ជាប់ខ្លួន 5. បិទគ្រប់ឧបករណ៍ និងភ្លើងទាំងអស់នៅក្នុងផ្ទះ 6. ចាក់សោរផ្ទះ។ ផ្លូវជម្លៀសគឺៈ [Evacuation Route]។ មជ្ឈមណ្ឌលជម្លៀសគឺបើកនៅ [Name and Location of Evacuation Center]។ សម្រាប់ព័ត៌មានបន្ថែម សូមតាមដានស្តាប់វិទ្យុ និងទូរទស្សន៍ក្នុងមូលដ្ឋាន បើកមើល **[url]** ឬទូរសព្ទទៅកាន់ **[###-###-####]**។

• សេវាព័ត៌មានអាកាសធាតុជាតិព្យាករណ៍ថានឹងមានទឹកជំនន់កើតឡើងនៅ [ទីតាំង] នៅក្នុងរយៈពេល 24 ទៀត។ នគរបាលកំពុងណែនាំឱ្យពលរដ្ឋដែលរស់នៅក្នុងតំបន់នេះត្រៀមខ្លួនសម្រាប់ការជម្លៀសដែលនឹងអាចកើតមានឡើងនៅក្នុងពេលណាមួយ។ សម្រាប់ព័ត៌មានអំពីរបៀបរៀបចំខ្លួនសម្រាប់ការជម្លៀស សូមចុចត្រង់នេះ។ ព័ត៌មានថ្មីៗដែលត្រូវតាមដាន។

*សារខ្លី*

• ការព្រមានអំពីទឹកជំនន់សម្រាប់ [location] សូមកុំទៅកាន់ទីតាំងនោះ។ សូមបត់ត្រឡប់ក្រោយ-ហាមចុះ។ សូមបន្តតាមដានព័ត៌មាន។

### **គំរូសារខ្លីអំពីជនបាញ់ប្រហារ**

*សារវែង*

• [Law Enforcement Agency] សូមរាយការណ៍អំពីជនបាញ់ប្រហារនៅជិត [location]។ សូមកុំទៅកាន់ទីតាំងនោះ។ ប្រសិនបើអ្នកស្ថិតនៅជិត [location] សូមចូលទៅក្នុងផ្ទះ សូមកុំចេញក្រៅ និងអនុវត្តវិធានការការពារដូចតទៅៈ 1. ចូលទៅក្នុងផ្ទះជាបន្ទាន់ និងកុំចេញក្រៅផ្ទះរបស់អ្នក 2. យកសត្វចិញ្ចឹមចូលក្នុងផ្ទះប្រសិនបើអ្នកអាចធ្វើបានលឿន។ 3. បិទបង្អួច និងទ្វារទាំងអស់ 4. សូមទាក់ទងទៅលេខ 911 ប្រសិនបើអ្នកពិតជាមានស្ថានភាពអាសន្នមែន ឬបានដឹង ឬបានឃើញសកម្មភាពគួរសង្ស័យ ឬនៅជិតទីតាំងរបស់អ្នក។ អ្នកនឹង

ទទួលបានព័ត៌មានអំពីពេលវេលាដែលអ្នកលែងប្រឈមនឹងគ្រោះថ្នាក់។ សម្រាប់ព័ត៌មានបន្ថែម សូមតាមដានស្ដាប់វិទ្យុ និងទូរទស្សន៍ក្នុងមូលដ្ឋាន បើកមើល **[url]** ឬទូរសព្ទទៅកាន់ **[###-###-####]**។

• ចាប់ពីម៉ោង 11ព្រឹក នគរបាលហាមសាធារណៈជនកុំឱ្យចូលទៅកាន់តំបន់ [insert location]។ មន្ត្រីកំពុងឆ្លើយតបចំពោះជនបាញ់ប្រហារ។ អ្នកដែលស្ថិតនៅជិតទីតាំងត្រូវស្វែងរកកន្លែងលាក់ខ្លួន និងបិទសំឡេងទូរសព្ទ។ ប្រសិនបើអ្នកនៅជាប់ជាមួយជនបាញ់ប្រហារ ត្រូវរត់ លាក់ខ្លួន ប្រយុទ្ធ។ សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់ **[link]** និងរង់ចាំស្ដាប់ការណែនាំបន្ថែម។

*សារខ្លី*

• ជនបាញ់ប្រហារនៅជិត [location]។ ហាមចូលទៅកាន់ទីតាំង ឬរត់ លាក់ខ្លួន វាយប្រយុទ្ធ។ សូមបន្តតាមដានព័ត៌មាន។